01048109

E330

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 12 / 2014
ម៉ោង (Time/Heure) : 14:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Claudia FENZ** |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | **សាធារណៈ** |

---

**ដីកាបញ្ជូនការប្រព្រឹត្តិរបស់មេធាវីការពារក្តី ខៀវ សំផន ទៅអង្គភាពមានសមត្ថកិច្ច**

---

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ**

នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**

សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្តីផ្តើម និង ប្រវត្តិនីតិវិធី

១. អង្គជំនុំជម្រះបានប្រឈមជាមួយនឹងទង្វើនានារបស់មេធាវីការពារក្តី ខៀវ សំផន ដែលនាំឲ្យមានការពន្យារកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២។

២. នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ ដែលចាប់ផ្តើមនៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤។ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយសម្រួលដល់ជនជាប់ចោទ អង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទចាប់ផ្តើមសវនាការដេញដោលលើភ័ស្តុតាង ក្រោយពីកាលបរិច្ឆេទចុងក្រោយថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ (ដោយទទួលបានការពន្យារពេល) នៃការដាក់សេចក្តីជូនដំណឹងលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១។ ដោយពិចារណាបន្ថែមទៅលើការខិតខំរបស់ភាគី ក្នុងការធ្វើសេចក្តីព្រាងសារណាលើបណ្តឹងសាទុក្ខរៀងៗខ្លួននោះ អង្គជំនុំជម្រះបានកាត់បន្ថយចំនួនថ្ងៃធ្វើសវនាការ មកត្រឹម ៣ ថ្ងៃ ក្នុង ១ សប្តាហ៍ ដែលរយៈពេលនៃការធ្វើសវនាការសរុបមានចំនួន ២៥ ថ្ងៃ គិតចាប់ពី ខែ តុលា ដល់ ខែ ធ្នូ ឆ្នាំ ២០១៤[1]។ កាលពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២។ បន្ទាប់ពីសហព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់រួចហើយ មេធាវីការពារក្តី ខៀវ សំផន បានចង្អុលបង្ហាញថា ពួកគេមិនចង់ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ទេ រហូតទាល់តែពួកគេ បានដាក់សារណាលើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ រួចរាល់សិន ដោយសារពួកគេពុំមានធនធានគ្រប់គ្រាន់[2]។ បន្ទាប់មកមេធាវីការពារក្តីបានដើរចេញពីបន្ទប់សវនាការ រួចហើយអង្គជំនុំជម្រះក៏បានប្រកាសផ្អាកកិច្ចដំណើរការនីតិវិធី។

៣. នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានរៀបចំកិច្ចប្រជុំរៀបចំសវនាការ (TMM) ដើម្បីពិភាក្សា *ក្នុងចំណោមនោះ* ពីមូលហេតុមួយចំនួនដែលមេធាវីការពារក្តីបានលើកឡើង ដើម្បីធ្វើយុត្តិកម្មចំពោះការប្រព្រឹត្តិរបស់ខ្លួន។ ទោះបីជាពួកគេ យកបញ្ហាកង្វះធនធានមកធ្វើជាមូលដ្ឋានគតិយុត្តិ

---

[1] *សូមមើល* ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ឯកសារ E316 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ ("ដីកាកំណត់កាលបរិច្ឆេទសវនាការ ខែ កញ្ញា ឆ្នាំ២០១៤")។ កាលបរិច្ឆេទសវនាការក្នុងសំណុំរឿង ០០២/០២ ឆ្នាំ ២០១៤ ឯកសារ E316.1 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ ("ដីកាកំណត់កាលបរិច្ឆេទសវនាការដែលបានចេញក្នុងខែ កញ្ញា ឆ្នាំ ២០១៤")។

[2] ប្រតិចារិក ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ៨៣, ៨៥ ដល់ ៨៧ (ភាសាអង់គ្លេស)។

ដើម្បីគាំទ្រការប្រព្រឹត្តិរបស់ខ្លួនក៏ដោយ ក៏មេធាវីជាតិ និងអន្តរជាតិការពារក្តី ខៀវ សំផន មិនបានចូលរួមក្នុងកិច្ចប្រជុំរៀបចំសវនាការនោះដែរ ដែលជាការរំលោភបំពានទៅលើដីកាបង្គាប់របស់អង្គជំនុំជម្រះ។

៤. នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការខកខានរបស់មេធាវីការពារក្តីក្នុងការចូលរួមកិច្ចប្រជុំរៀបចំសវនាការ កាលពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ គឺជាកំហុសវិជ្ជាជីវៈ និងបានធ្វើការព្រមានដល់មេធាវីការពារក្តី អនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង។ ដើម្បីផ្តល់ឱកាសបន្ថែមទៀតដល់មេធាវីការពារក្តី ក្នុងការពន្យល់ពីអំណះអំណាងរបស់ខ្លួនទាក់ទងនឹងបញ្ហាធនធានមិនគ្រប់គ្រាន់នោះ អង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ និងបានបង្គាប់ឲ្យមេធាវីការពារក្តីមានវត្តមាន[3]។ មេធាវីការពារក្តី ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី ២៨ ខែ តុលា និងបានធ្វើសេចក្តីសន្និដ្ឋាន*ក្នុងចំណោមនោះ* ពីមូលហេតុនៃការប្រព្រឹត្តរបស់ខ្លួនពីពេលមុន និងការអះអាងពីការដែលខ្លួន មិនមានបំណងក្នុងការចូលរួមសវនាការលើអង្គសេចក្តីនាពេលខាងមុខក្នុងសំណុំរឿង ០០២/០២ ទេ។

៥. នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានបដិសេធសេចក្តីសន្និដ្ឋានទាំងនេះ និងបានបង្គាប់ឲ្យភាគីទាំងអស់មានវត្តមាននៅក្នុងសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ដែលចាប់ផ្តើមពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤។ អង្គជំនុំជម្រះបានជូនដំណឹងបន្ថែមទៀតដល់មេធាវីការពារក្តី ខៀវ សំផន ថា អង្គជំនុំជម្រះនឹងចាត់វិធានការម៉ឺងម៉ាត់ ប្រសិនបើពួកគេនៅតែមិនអនុវត្តតាមដីកាបង្គាប់ឲ្យមានវត្តមានក្នុងសវនាការនោះទេ[4]។ ថ្វីត្បិតតែយ៉ាងនេះក្តី ដើម្បីជួយសម្រួលបន្ថែមទៀតដល់ ខៀវ សំផន និងមេធាវីការពារក្តីរបស់គាត់ និងដោយពិចារណាដល់សិទ្ធិរបស់ភាគីផ្សេងទៀតក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីឆាប់រហ័សនោះ អង្គជំនុំជម្រះបានកាត់បន្ថយចំនួនថ្ងៃធ្វើសវនាការបន្ថែមទៀត មកត្រឹម ពីរថ្ងៃ ក្នុងមួយសប្តាហ៍[5] ដែលចំនួនថ្ងៃធ្វើ សវនាការសរុបនៅសល់តែចំនួន ១០ ថ្ងៃប៉ុណ្ណោះ រហូតដល់ដំណាច់ឆ្នាំ ២០១៤។

---

[3] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "ការព្រមានមេធាវីការពារក្តី នួន ជា និង ខៀវ សំផន" ឯកសារ E320 ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤ ("ការព្រមានរបស់អង្គជំនុំជម្រះសាលាដំបូង") កថាខណ្ឌ៦,៨។

[4] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "សេចក្តីសម្រេចបន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤" ឯកសារ E320/1 ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចបន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤")។

[5] *សូមមើល* ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើភស្តុតាង ឯកសារ E322 ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ("ដីកាកំណត់កាលបរិច្ឆេទសវនាការខែ វិច្ឆិកា ឆ្នាំ ២០១៤)។

01048112



៦. មេធាវីការពារក្តី ខៀវ សំផន មិនមានវត្តមាននៅក្នុងសវនាការនៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ដែលបានកំណត់នោះទេ ដែលការណ៍នេះគឺជាការរំលោភបំពានដោយផ្ទាល់ទៅលើដីកាបង្គាប់របស់អង្គជំនុំជម្រះ។ ជនជាប់ចោទ ខៀវ សំផន ដែលមានវត្តមាននៅក្នុងសវនាការ បានបញ្ជាក់ថា មេធាវីការពារក្តីអន្តរជាតិរបស់គាត់ស្ថិតនៅទីក្រុងប៉ារីស ហើយគាត់បានណែនាំឱ្យមេធាវីការពារក្តីរបស់គាត់ផ្តោតការយកចិត្តទុកដាក់ទៅលើការព្រាងសារណាលើបណ្តឹងសាទុក្ខប្រឆាំងទៅនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ និងមិនឱ្យមានវត្តមាននៅក្នុងសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ទេ។ គាត់បានអះអាងបន្ថែមទៀតថា ទាំងរូបគាត់ និងមេធាវីការពារក្តីរបស់គាត់មិនមានធនធានគ្រប់គ្រាន់ ដើម្បីធ្វើការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ និងចូលរួម ក្នុងសវនាការសំណុំរឿង ០០២/០២ ក្នុងពេលតែមួយបាននោះទេ[6]។

៧. អង្គជំនុំជម្រះបានជូនដំណឹងដល់ ខៀវ សំផន បន្ថែមទៀតថា អង្គជំនុំជម្រះអាចនឹងចាត់តាំងមេធាវីដែលតែងតាំងដោយតុលាការ ប្រសិនបើក្នុងពេលនេះ ឬពេលណាមួយនាពេលអនាគត គាត់ណែនាំមេធាវីរបស់ខ្លួនមិនឱ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ នោះ[7]។ បន្ទាប់មកអង្គជំនុំជម្រះបានបង្គាប់ឱ្យជនជាប់ចោទ ជូនដំណឹងមកអង្គជំនុំជម្រះវិញត្រឹមថ្ងៃបន្ទាប់ ថាតើគាត់ដកការណែនាំ មិនឱ្យមេធាវីរបស់ខ្លួនចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ដែរ ឬយ៉ាងណា។ ជាចុងក្រោយអង្គជំនុំជម្រះបានកត់សម្គាល់ថា កំហុសវិជ្ជាជីវៈរបស់មេធាវីនឹងត្រូវលើកឡើងនៅក្នុងដីកាបង្គាប់មួយដោយឡែក។ កាលពីថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ជនជាប់ចោទបានជូនដំណឹងមកអង្គជំនុំជម្រះថា ការណែនាំរបស់គាត់ចំពោះមេធាវីរបស់ខ្លួនមិនមានការប្រែប្រួលទេ[8]។

៨. ហេតុដូច្នេះ នៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានតែងតាំងជាថ្មីចំពោះមេធាវីការពារក្តី ខៀវ សំផន ក្នុងនាមជាមេធាវីដែលចាត់តាំងដោយតុលាការ។ ការចាត់តាំងមេធាវីជាថ្មីនេះតម្រូវថា មេធាវីការពារក្តីចូលរួមយ៉ាងមានប្រសិទ្ធភាពនៅក្នុងសំណុំរឿង ០០២/០២ រួមទាំងការចូលរួមក្នុងសវនាការទាំងអស់ផងដែរ។ ប្រសិនបើការណែនាំរបស់ ខៀវ សំផន នាំឱ្យ ឬមានបំណងនាំឱ្យមានការរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី ឬផ្ទុយទៅនឹងផលប្រយោជន៍យុត្តិធម៌ មេធាវីមានកាតព្វកិច្ចមិនធ្វើតាមការណែនាំ

[6] ប្រតិចារឹក ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៥, ៨-៩ (ភាសាអង់គ្លេស)។

[7] ប្រតិចារឹក ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (ព្រាង) ទំព័រ ១០ ដល់ ១២, ១៤-១៥ (ភាសាអង់គ្លេស)។

[8] របាយការណ៍របស់អង្គភាពគាំពារការការពារក្តីស្តីពីការពិគ្រោះយោបល់ជាមួយ ខៀវ សំផន ឯកសារ E320/1/2 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៤ កថាខណ្ឌ ២។

01048113



នោះទេ[9]។ អង្គជំនុំជម្រះបានបង្គាប់បន្ថែមទៀតដល់មេធាវីចាត់តាំងដោយតុលាការ ឱ្យមានវត្តមាននៅក្នុងសវនាការលើអង្គសេចក្តីដែលបានកំណត់នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

៩. នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ មេធាវីការពារក្តី ខៀវ សំផន បានជូនដំណឹងមកអង្គជំនុំជម្រះតាមរយៈលិខិតថា ពួកគេនឹងមិនទទួលយកការតែងតាំងជាមេធាវីដែលចាត់តាំងដោយតុលាការនោះទេ ដោយសារប្រការនេះនឹងរំលោភបំពានដល់ឯករាជ្យរបស់ពួកគេ តែប្រែដោយមិនត្រឹមត្រូវលើកិច្ចសន្យាការងារដែលពួកគេបានចុះហត្ថលេខាជាមួយអង្គការសហប្រជាជាតិរួចហើយ និងបង្ខំឱ្យពួកគេរំលោភបំពានដល់កាតព្វកិច្ច និងក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន ដោយប្រព្រឹត្តផ្ទុយនឹងផលប្រយោជន៍របស់កូនក្តីខ្លួន។ ពួកគេបានថ្លែងបន្ថែមទៀតថា ពួកគេនឹងមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធីទេ រហូតទាល់តែពួកគេបានដាក់សារណាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង00២/0១ ដែលផុតកំណត់ត្រឹមថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ រួចរាល់សិន ដោយអះអាងថា នេះជាការចាំបាច់ ដើម្បីរក្សាយ៉ាងមានប្រសិទ្ធភាពនូវសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវពេលវេលាគ្រប់គ្រាន់សម្រាប់ការរៀបចំការការពារក្តីរបស់ខ្លួន[10]។ ដូចដែលបានជម្រាបតាមរយៈលិខិតនេះ មេធាវីដែលចាត់តាំងដោយតុលាការមិនមានវត្តមាននៅក្នុងសវនាការនៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ នោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា អង្គជំនុំជម្រះនឹងពិចារណាបញ្ជូនកំហុសវិជ្ជាជីវៈរបស់មេធាវីការពារក្តីទៅអង្គភាពមានសមត្ថកិច្ច អនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង[11]។ ដោយផ្អែកលើលក្ខខណ្ឌតម្រូវនៅក្នុងច្បាប់នៃប្រទេសកម្ពុជាថា ជនជាប់ចោទត្រូវតំណាងដោយមេធាវី[12] និងដោយសារតែមិនអាចរកបានមេធាវី ដែលយល់ដឹងច្បាស់លាស់ពីសំណុំរឿងនេះ អង្គជំនុំជម្រះមិនមានជម្រើសណាផ្សេងក្រៅពីផ្អាកកិច្ចដំណើរការនីតិវិធីរហូតដល់ខែ មករា ឆ្នាំ ២០១៥ ឡើយ។

១០. នៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ២០១៤ អង្គជំនុំជម្រះបានកត់សម្គាល់ថា ការខាតបង់រយៈពេលនៃដំណើរការសវនាការជំនុំជម្រះជាង ២ ខែ គឺជាពេលវេលាដ៏ច្រើន ក្នុងរឿងក្តីមួយដែល ជនជាប់ចោទ សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី សុទ្ធតែមានវ័យកាន់តែចាស់ ហើយការពន្យារពេលណាមួយអាចនឹងនាំឱ្យ

---

[9] សេចក្តីសម្រេចស្តីពីការតែងតាំងមេធាវីដែលចាត់តាំងដោយតុលាការសម្រាប់ ខៀវ សំផន ឯកសារ E320/2 ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចស្តីពីមេធាវីដែលចាត់តាំងដោយតុលាការ") កថាខណ្ឌ ១៨។

[10] *លិខិតជូនទៅអង្គជំនុំជម្រះសាលាដំបូង* ឯកសារ E320/2/1 ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ("លិខិតពីមេធាវីការពារក្តី ខៀវ សំផន")។*សូមមើលផង*ដែរគោលជំហររបស់លោក ខៀវ សំផន បន្ទាប់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង E320/1 ឯកសារ E320/1/1 ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ("គោលជំហររបស់ ខៀវ សំផន")។

[11] ប្រតិចារិកសវនាការថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤

[12] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣០១ ("ជំនួយពីមេធាវីត្រូវតែមានដាច់ខាត នៅក្នុងករណីដូចតទៅ៖ ១-ករណីបទឧក្រិដ្ឋ ...")។

ពួកគេមិនអាចចូលរួមក្នុងការជំនុំជម្រះបាន។ ដើម្បីចៀសវាងមិនឱ្យស្ថានភាពដដែលនេះកើតមាននាពេលអនាគតទៀត អង្គជំនុំជម្រះបានបង្គាប់ឱ្យចាត់តាំងមេធាវីអន្តរជាតិមួយរូប និងមេធាវីជាតិមួយរូប ជាមេធាវីប្រចាំការចាត់តាំងដោយតុលាការ សម្រាប់ ខៀវ សំផន[13]។

## ២. ច្បាប់ជាធរមាន

១១. មាត្រា ២១(៣) នៃកិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក ចែងថា៖

> មេធាវីណាដែលមានសញ្ជាតិខ្មែរ ឬ មិនមែនខ្មែរ ដែលត្រូវជួលឬចាត់តាំងឱ្យធ្វើការជាមួយជនសង្ស័យ ឬ ជនជាប់ចោទ ក្នុងការការពារក្ដីរបស់ខ្លួន ត្រូវអនុវត្តតាមកិច្ចព្រមព្រៀងនេះ ច្បាប់កម្ពុជាស្ដីពីលក្ខន្តិកៈមេធាវី បទដ្ឋាន និងក្រមសីលធម៌វិជ្ជាជីវៈច្បាប់ដែលគេទទួលស្គាល់។

១២. វិធាន ៣៥ នៃវិធានផ្ទៃក្នុងចែងថា៖

> ១. អង្គជំនុំជម្រះវិសាមញ្ញអាចដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនូវជនណាម្នាក់ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំងបុគ្គលដែលមានចែងដូចខាងក្រោម:
>
> [...]
>
> ខ-ដោយគ្មានមូលហេតុសមស្រប បុគ្គលដែលមិនគោរពតាមសេចក្ដីបង្គាប់ឱ្យចូលរួមក្នុងដំណើរការជម្រះក្ដី ឬមិនផ្ដល់ឯកសារ ឬភស្តុតាងផ្សេងទៀតឱ្យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ។
>
> [...]
>
> ៥. ប្រសិនបើរកឃើញថា មេធាវីណាម្នាក់បានប្រព្រឹត្តអំពើណាមួយដូចមានចែងក្នុងអនុវិធាន ១ ខាងលើ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះដែលរកឃើញកំហុសនោះ អាចកំណត់ថាការប្រព្រឹត្តអំពើនេះគឺជាកំហុសវិជ្ជាជីវៈរបស់មេធាវីដូចមានចែងក្នុងវិធាន ៣៨។

---

[13] សេចក្ដីសម្រេចស្ដីពីការតែងតាំងមេធាវីប្រចាំការដោយតុលាការសម្រាប់ ខៀវ សំផន ឯកសារ E321/2 ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤។

១៣. វិធាន ៣៨ នៃវិធានផ្ទៃក្នុងចែងថា៖

១. សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ក្រោយពេលព្រមាន អាចដាក់ទណ្ឌកម្ម ឬបដិសេធក្នុងការចូលរួមសវនាការចំពោះមេធាវីណាមួយ ប្រសិនបើយល់ឃើញថា ការប្រព្រឹត្តិរបស់មេធាវីរូបនោះ ជាការប្រមាថមើលងាយ រាំងស្ទះដល់កិច្ចដំណើរការនីតិវិធី រំលោភទៅលើរឿងក្តី ឬ ផ្ទុយទៅនឹងមាត្រា ២១-៣ នៃកិច្ចព្រមព្រៀង។

២. សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាចបញ្ជូនករណីកំហុសវិជ្ជាជីវៈនេះទៅអង្គភាពមានសមត្ថកិច្ច។

១៤. អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក ធ្លាប់បានសម្រេចថា "វិធាន ៣៨ នៃវិធានផ្ទៃក្នុង មានអត្ថន័យដែលធានាថា កិច្ចដំណើរការនីតិវិធីមិនត្រូវបានរាំងស្ទះដោយឥរិយាបថប្រមាថមើលងាយ និង/ឬ បង្អាក់ ឬ ដោយការប្រព្រឹត្តិណាមួយ ដែលចាត់ទុកថាជាការរំលោភបំពានលើនីតិវិធី ពីព្រោះការប្រព្រឹត្តិនោះ អាចនាំឱ្យមានគ្រោះថ្នាក់ដល់ការគ្រប់គ្រងភាពយុត្តិធម៌"[14]។ វិធាន ៣៥(៥) និង វិធាន ៣៨ នៃវិធានផ្ទៃក្នុងមានគោលបំណងក្នុងការបញ្ចៀសនូវការរាំងស្ទះ ឬការពន្យារពេលដែលមិនចាំបាច់ ដែលបណ្តាលមកពីមេធាវីរួមទាំងមេធាវីការពារក្តីជនជាប់ចោទផងដែរ[15]។ នៅក្នុងឧទាហរណ៍ជាក់លាក់ពីរ ក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានសម្រេចថា ការណ៍ដែលអតីតមេធាវីការពារក្តី ខៀវ សំផន បដិសេធមិនមានវត្តមាននៅក្នុងសវនាការដែលត្រូវបានកំណត់កាលបរិច្ឆេទនោះ ចាត់ទុកថាជាការរំលោភបំពានទៅលើនីតិវិធី និងជាការរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីទៅតាមអត្ថន័យនៃវិធាន ៣៨ នៃវិធានផ្ទៃក្នុង[16]។ សេចក្តីសម្រេចទាំងពីរនេះស្របទៅនឹងទម្លាប់អនុវត្តរបស់តុលាការអន្តរជាតិនានា ដែលបានរកឃើញថា ការខក

[14] ការព្រមានចំពោះសហមេធាវីអន្តរជាតិ (អបជ) ឯកសារ C26/5/22 ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ កថាខណ្ឌ ២៥។

[15] *សូមមើលផងដែរ* វិធាន ៨៥ នៃវិធានផ្ទៃក្នុង ("ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវដឹកនាំកិច្ចដំណើរការនីតិវិធី និងជួយសម្រួលដល់ការធ្វើអន្តរាគមន៍របស់ចៅក្រមផ្សេងទៀត។ ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនឱ្យប្រព្រឹត្តទៅបានដោយសេរី។ ដោយមានការពិគ្រោះយោបល់ជាមួយចៅក្រមផ្សេងទៀត ប្រធានសវនាការអាចបដិសេធនូវរាល់នីតិវិធីដែលនាំឱ្យមានការពន្យារពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំទៅដល់ការស្វែងរកការពិត")។

[16] សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ឯកសារ C26/I/25 ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៨ កថាខណ្ឌ ១៥។ ការព្រមានចំពោះសហមេធាវីអន្តរជាតិ (អបជ) ឯកសារ C26/5/22 ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ កថាខណ្ឌ ៣១។

ខាងរបស់មេធាវីការពារក្ដីមិនបានចូលរួមក្នុងសវនាការដែលត្រូវបានកំណត់កាលបរិច្ឆេទ អាចនាំឱ្យមានការដាក់ទណ្ឌកម្មបាន[17]។

១៥. ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដូចនឹងវិធានផ្ទៃក្នុង អ.វ.ត.ក និងបទប្បញ្ញត្តិនានានៅក្នុងច្បាប់នៃប្រទេសបារាំងដែរ ប្រមើលមើលបន្ថែមទៀតពីលទ្ធភាពនៃការដាក់ទណ្ឌកម្មប្រឆាំងនឹងមេធាវីដែលរំលោភបំពានលើកាតព្វកិច្ចក្រមសីលធម៌ ឬ វិជ្ជាជីវៈរបស់ខ្លួន[18]។ ក្រមសីលធម៌មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាចែង*ក្នុងចំណោមនោះ*ថា មេធាវីត្រូវអនុវត្តតាមវិធាននីតិវិធី និងបទបញ្ជារបស់តុលាការ និងមិនត្រូវបង្កឱ្យមានការពន្យារនីតិវិធីតុលាការណាមួយ ដោយការធ្វេសប្រហែស ឬមូលហេតុមិនសមហេតុផលដែលអាចប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌នោះឡើយ[19]។ ការប្រព្រឹត្តខុសវិជ្ជាជីវៈដោយមេធាវីដែលបានចុះបញ្ជីនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC) អាចនឹងត្រូវទទួលការដាក់ទណ្ឌកម្មពីក្រុមប្រឹក្សាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា[20]។ បន្ថែមពីលើនេះទៀត ក្នុងករណីដែលការប្រព្រឹត្តខុសពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក បញ្ហាវិន័យអាចនឹងត្រូវដោះ

---

[17] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Nahimana សាលដីកាលើបណ្ដឹងសាទុក្ខ សំណុំរឿងលេខ ICTR-96-11-A ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ១៣៩ (ភាសាអង់គ្លេស)។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Musema សេចក្ដីសម្រេចដកមេធាវីដែលត្រូវបានតែងតាំងចេញ និងអនុញ្ញាតឱ្យរដ្ឋអាជ្ញាកំណត់ជាបណ្ដោះអាសន្ននូវព័ត៌មានរបស់សាក្សីខ្លួន សំណុំរឿងលេខ ICTR-96-13-I ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៨ (ភាសាអង់គ្លេស)។

[18] ច្បាប់ស្ដីពីគណៈមេធាវីកម្ពុជា ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៥ មាត្រា ៥៩ ("ត្រូវទទួលទណ្ឌកម្មជាបទវិន័យ ចំពោះមេធាវីណាដែលប្រព្រឹត្តល្មើសនឹងវិធាននៃវិជ្ជាជីវៈ ឬប្រព្រឹត្តអំពើណាមួយដែលប៉ះពាល់ដល់សីលធម៌ ឬកិត្តិយសមេធាវី ទោះបីប្រព្រឹត្តក្រៅពីការប្រកបវិជ្ជាជីវៈរបស់ខ្លួនក៏ដោយ")។ ចំពោះច្បាប់បារាំង *សូមមើល*មាត្រា ១.៣ និង ១.៤ នៃ *Réglement Intérieur National de la profession d'avocat : Les principes essentiels de la profession guident le comportement de l'avocat en toutes circonstances. L'avocat exerce ses fonctions avec dignité, conscience, indépendance, probité et humanité, dans le respect des termes de son serment. Il respecte en outre, dans cet exercice, les principes d'honneur, de loyauté, de désintéressement, de confraternité, de délicatesse, de modération et de courtoisie. Il fait preuve, à l'égard de ses clients, de compétence, de dévouement, de diligence et de prudence. La méconnaissance d'un seul de ces principes, règles et devoirs, constitue [...] une faute pouvant entraîner une sanction disciplinaire*។

[19] ក្រមសីលធម៌មេធាវី នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមសីលធម៌គណៈមេធាវីកម្ពុជា") មាត្រា ៣៧, ៣៩។

[20] ច្បាប់ស្ដីពីគណៈមេធាវីកម្ពុជា មាត្រា ១៩ ("ក្រុមប្រឹក្សាគណៈមេធាវីពិនិត្យដោះស្រាយគ្រប់បញ្ហា ដែលពាក់ព័ន្ធទៅការអនុវត្តន៍វិជ្ជាជីវៈមេធាវី។ ក្រុមប្រឹក្សាគណៈមេធាវីធានាការបំពេញភារកិច្ចនិងការការពារសិទ្ធិរបស់មេធាវី។ ក្រុមប្រឹក្សាគណៈមេធាវីមានភារកិច្ចអាទិ៍ដូចតទៅ៖ ធានាការគោរពវិន័យ និងការដាក់វិន័យ ...")។ *សូមមើលផងដែរ* លិខិតពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាទាក់ទងនឹងការដាក់ទណ្ឌកម្មមេធាវីដែលប្រព្រឹត្តកំហុសវិជ្ជាជីវៈ ឯកសារ E320/3 ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤ (ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤)។

ស្រាយដោយ អ.វ.ត.ក និង/ឬ អាចបញ្ជូនទៅគណៈមេធាវីកម្ពុជា និង/ឬ គណៈមេធាវីនៃប្រទេសណាមួយដែលមេធាវីបរទេសនោះបានចុះបញ្ជី។

## ៣. សំអាងហេតុ

១៦. អង្គជំនុំជម្រះសន្និដ្ឋានថា ការប្រព្រឹត្តិរបស់មេធាវីការពារក្តី ខៀវ សំផន ដែលក្នុងនោះមាន លោកមេធាវី គង់ សំអុន មេធាវី Arthur VERCKEN និង មេធាវី Anta GUISSÉ ដែលរំលោភបំពានលើដីការបស់តុលាការដែលបង្គាប់ឱ្យចូលរួម និងជួយកូនក្តីរបស់ខ្លួននៅក្នុងសវនាការដែលបានកំណត់កាលបរិច្ឆេទ គឺជាការធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីយ៉ាងធ្ងន់ធ្ងរ និងដោយមានចេតនា។ អង្គជំនុំជម្រះកត់សម្គាល់ថា មេធាវីការពារក្តី ខៀវ សំផន ធ្លាប់ត្រូវបានព្រមានពីពេលមុនរួចមកហើយដោយអង្គជំនុំជម្រះអនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង ហើយនៅតែបន្តការប្រព្រឹត្តិបែបនេះទៀត[21] ដោយបដិសេធមិនព្រមចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា និង ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤[22]។ ដោយសារតែការប្រព្រឹត្តិរបស់មេធាវីការពារក្តីចាប់ពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ មកចិរវេលាសវនាការចំនួន ២៥ ថ្ងៃ ក្នុងរយៈពេល ១០ សប្តាហ៍ត្រូវបានលុបចោល[23]។ ចំណុចនេះជាបញ្ហាសំខាន់ ដោយពិចារណាដល់វ័យរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង ជនជាប់ចោទ ក្នុងរឿងក្តីនេះ ហើយដោយសារជាការចាំបាច់ដែល អ.វ.ត.ក ត្រូវប្រើប្រាស់ពេលវេលាដែលមាន ដើម្បីធានាឱ្យមានសេចក្តីសម្រេចជាស្ថាពរទៅលើបទចោទដែលនៅសេសសល់ឱ្យបានឆាប់តាមតែអាចធ្វើទៅបាន[24]។ ដូចដែលអង្គ-ជំនុំជម្រះធ្លាប់បានកត់សម្គាល់រួចមកហើយថា ការប្រព្រឹត្តរបស់មេធាវីការពារក្តីបានធ្វើឱ្យមានការលំបាក

---

[21] ការព្រមានរបស់អង្គជំនុំជម្រះសាលាដំបូង។

[22] ប្រតិចារឹក ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ២ (ភាសាអង់គ្លេស)។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ១ (ភាសាអង់គ្លេស)។

[23] *សូមមើល* ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការ ខែ កញ្ញា ឆ្នាំ ២០១៤។ កាលបរិច្ឆេទសវនាការដែលបានចេញក្នុង ខែ កញ្ញា ឆ្នាំ ២០១៤។

[24] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ (អជតក) ឯកសារ E163/5/1/13 ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើវិសាលភាពសំណុំរឿង០០២/០១") កថាខណ្ឌ ៥១។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ (អជតក) ឯកសារ E284/4/8 ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ("សេចក្តីសម្រេចលើកទី២ របស់ អ.ជ.ត.ក លើការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២") កថាខណ្ឌ ៧២។

ដល់សាក្សី និង ដើមបណ្ដឹងរដ្ឋប្បវេណី ការរំខានដល់ភាគី និងការចំណាយជាច្រើនបន្ថែមទៀតសម្រាប់ អ.វ.ត.ក[25]។

១៧. មេធាវីការពារក្ដី ខៀវ សំផន អះអាងថា ពួកគេគ្រាន់តែពន្យារពេលរហូតដល់សារណាលើបណ្ដឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០១ បានដាក់រួចរាល់ ដែលត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ប៉ុណ្ណោះ[26]។ នេះជាការពន្យារពេលយ៉ាងច្រើន ដោយពិចារណាថា ជាការចាំបាច់ដែល អ.វ.ត.ក ត្រូវប្រើប្រាស់ពេលវេលាដែលមាន ដើម្បីសម្រេចជាស្ថាពរលើបទចោទដែលនៅសេសសល់ឱ្យបានឆាប់តាមតែអាចធ្វើទៅបាន[27]។ ជាងនេះទៀត មិនមានមូលដ្ឋានគតិយុត្តិណាមួយសម្រាប់គាំទ្រដល់ទឡ្ហីករណ៍ដែលបានលើកឡើងដោយមេធាវីការពារក្ដី ដើម្បីធ្វើយុត្តិកម្មដល់ការប្រព្រឹត្តិរបស់ខ្លួននោះទេ ដែលក្នុងនោះមេធាវីការពារក្ដីបានលើកឡើងនូវអំណះអំណាងដូចជា មិនមានធនធានគ្រប់គ្រាន់ ខៀវ សំផន មិនអាចចូលរួមឱ្យបានពេញលេញក្នុងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ និងភារកិច្ចរបស់មេធាវីការពារក្ដីក្នុងការបង្ហាញភាពស្មោះត្រង់ចំពោះកូនក្ដីរបស់ខ្លួន ដែលរារាំងមិនឱ្យពួកគេអាចធ្វើអ្វីផ្ទុយពីផលប្រយោជន៍របស់កូនក្ដីបាន។ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ អង្គជំនុំជម្រះសូមលើកឡើងនូវអំណះអំណាងទាំងនេះដូចខាងក្រោម។

## ៣.១ ធនធានគ្រប់គ្រាន់សម្រាប់មេធាវីការពារក្ដី

១៨. នៅក្នុងសារណាចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៤ និងក្នុងអំឡុងពេលសវនាការថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ មេធាវីការពារក្ដី ខៀវ សំផន បានលើកឡើងថា ធនធានដែលមាន គឺមិនគ្រប់គ្រាន់សម្រាប់ការការពារកូនក្ដីរបស់ខ្លួនឱ្យមានប្រសិទ្ធភាពនោះទេ ដោយសារត្រូវចូលរួមក្នុងសវនាការសំណុំរឿង ០០២/០២ ផង ហើយស្របពេលជាមួយគ្នានេះ ត្រូវរៀបចំបញ្ចប់សារណាលើបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ផង[28]។ អាស្រ័យហេតុនេះ តាមការណែនាំរបស់ ខៀវ សំផន ពួកគេ

---

[25] សេចក្ដីសម្រេចស្ដីពីមេធាវីដែលចាត់តាំងដោយតុលាការ កថាខណ្ឌ ១៦។ ការចំណាយទាំងនេះទាក់ទងនឹងការពន្យារពេលកិច្ចដំណើរការនីតិវិធីជិតបីខែ រួមទាំងការចំណាយរយៈពេលវែងដែលភ្ជាប់ជាមួយនឹងការតែងតាំងមេធាវីប្រចាំការ។

[26] ប្រតិចារឹក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ២៤ ដល់ ២៥ (ភាសាអង់គ្លេស)។

[27] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើវិសាលភាពសំណុំរឿង០០២/០១ កថាខណ្ឌ ៥១។ សេចក្ដីសម្រេចលើកទី២ របស់ អ.ជ.ត.ក លើការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២ កថាខណ្ឌ ៧២, ៧៦។

[28] *សំណើជាបន្ទាន់សុំឱ្យពិចារណាឡើងវិញ លើដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០២* ឯកសារ E314/5/1 ចុះថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ២, ៧ ដល់ ៩, ១៤។ ប្រតិចារឹក ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ៨១ ដល់ ៨៣, ៨៥ ដល់ ៨៦ (ភាសាអង់គ្លេស)។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤

01048119



ជ្រើសរើសយកការរៀបចំសារណាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ និងមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ទេ។

១៩. របាយការណ៍មិនគាំទ្រដល់ទឡ្ហីករណ៍របស់មេធាវីការពារក្តីដែលថា ពួកគេមិនមានធនធានគ្រប់គ្រាន់នោះទេ។ អង្គជំនុំជម្រះកត់សម្គាល់ថា ការចំណាយសរុបសម្រាប់មេធាវីការពារក្តីមួយក្រុមៗនៅ អ.វ.ត.ក គឺប្រហែល ៦០០.០០០ ដុល្លារ ក្នុងមួយឆ្នាំ[29]។ មេធាវីការពារក្តី ខៀវ សំផន បានទទួលប្រាក់កម្រៃពេញលេញក្នុងអំឡុងពេល ៨ ខែ ខណៈដែលអង្គជំនុំជម្រះបានកំពុងរៀបចំសេចក្តីព្រាងសាលក្រមក្នុងសំណុំរឿង ០០២/០១ ហើយដែលក្នុងពេលនោះ មានពេលវេលាត្រឹមតែបួនថ្ងៃប៉ុណ្ណោះ សម្រាប់ការរៀបចំសំណុំរឿង ០០២/០២[30]។ មេធាវីការពារក្តី ខៀវ សំផន ទទួលបានការជូនដំណឹងរួចហើយថា សំណុំរឿង ០០២/០២ នឹងចាប់ផ្តើមក្នុងពេលឆាប់ៗខាងមុខនេះ ហើយជាការពិត ភាគីផ្សេងៗទៀត ដែលស្ថិតនៅក្នុងកាលៈទេសៈស្រដៀងគ្នានេះដែរ បានត្រៀមរៀបចំខ្លួនរួចហើយ សម្រាប់ការចូលរួមក្នុងសវនាការសំណុំរឿង ០០២/០២ ដែលត្រូវចាប់ផ្តើមនៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤[31]។

២០. មុនកាលបរិច្ឆេទនេះ មេធាវីការពារក្តី ខៀវ សំផន មិនបានជូនដំណឹងមកអង្គជំនុំជម្រះ នូវតម្រូវការធនធានបន្ថែមនោះទេ[32]។ ក្រោយពេលដែលមេធាវីការពារក្តីលើកឡើងនូវបញ្ហាធនធានជាលើកដំបូង អង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការដើម្បីពិភាក្សាពីបញ្ហានេះ[33]។ មេធាវី

ទំព័រ ១៧ (ភាសាអង់គ្លេស) ("ការធ្វើការលើរឿងក្តីទីពីរ [សំណុំរឿង ០០២/០២] មានសារៈសំខាន់តិចជាង។ អ្វីដែលមានសារៈសំខាន់បំផុតគឺ ការធ្វើការលើបណ្តឹងសាទុក្ខរបស់គាត់")។ លិខិតពីមេធាវីការពារក្តី ខៀវ សំផន ទំព័រ ១។

[29] ប្រតិចារឹក ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ២៥ (ភាសាអង់គ្លេស) (សាធារណៈ)។

[30] ប្រតិចារឹក ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ១៤ (ភាសាអង់គ្លេស) (សាធារណៈ)។

[31] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់សំណុំរឿង ០០២/០២ និងការកំណត់កាលបរិច្ឆេទនៃការដាក់ឯកសារនាពេលខាងមុខ" ឯកសារ E301/5 ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣។ សំណុំរឿង ០០២/០២ -- ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូង (លំអិត) ឯកសារ E301/5.1 ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១៣ (ដោយចង្អុលបង្ហាញពីជំហានចុងក្រោយមុននឹងសវនាការលើអង្គសេចក្តី គឺសវនាការបឋម)។ ដីកាកំណត់កាលបរិច្ឆេទសវនាការបឋមបន្ថែម ឯកសារ E311 ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៤។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ៣៦ (ភាសាអង់គ្លេស) (មេធាវីការពារក្តី នួន ជា បានរៀបចំសម្រាប់សវនាការលើអង្គសេចក្តីនៅខែ មីនា ឆ្នាំ ២០១៤)។

[32] មេធាវីបានជំទាស់ចំពោះការចាប់ផ្តើមដំណើរការសវនាការគឺជាបញ្ហាផ្លូវច្បាប់ រហូតដល់សាលក្រមក្នុងសំណុំរឿង ០០២/០១ អាជ្ញាអស់ជំនុំ *(res judicata)* តែមិនបានលើកឡើងពីកង្វះខាតធនធានហិរញ្ញវត្ថុ ឬធនធានមនុស្សទេ។

[33] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងផ្ញើជូនភាគីនៃសំណុំរឿង ០០២ ឯកសារ E320.1 ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤។ មេធាវីបានលើកឡើងថា អង្គភាពគាំពារការការពារក្តីមិនលើកទឹកចិត្តឲ្យពួកគេដាក់សំណើសុំដីកាបង្គាប់ឲ្យដាក់ទណ្ឌកម្មប្រឆាំងមេធាវីការពារក្តី ខៀវ សំផន /សាធារណៈ/ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤

ការពារក្តី ខៀវ សំផន មិនបានចូលរួមកិច្ចប្រជុំរៀបចំសវនាការនេះទេ ហើយក៏មិនបានផ្តល់នូវមូលហេតុណាមួយអំពីការមិនចូលរួមរបស់ពួកគេដែរ[34]។ ទោះបីជា នៅខែ តុលា ឆ្នាំ ២០១៤ អង្គភាពគាំពារការការពារក្តីបានលើកសំណើមួយទៅផ្នែករដ្ឋបាល ដោយស្នើសុំការចំណាយបន្ថែម ១៦ % លើការងារបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ និងកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង ០០២/០២[35]ក៏ដោយ ក៏មេធាវីការពារក្តីមិនបានជូនដំណឹងដល់អង្គជំនុំជម្រះ អំពីសំណើសុំនេះ មុនពេលដើរចេញពីសវនាការនៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ នោះដែរ។ ទោះបីជាប្រាក់កម្រៃបន្ថែមនេះត្រូវបានផ្តល់ជូនហើយក្តី ក៏មេធាវីការពារក្តីពោលថា ពួកគេនឹងមិនផ្លាស់ប្តូរជំហររបស់ខ្លួន ពាក់ព័ន្ធនឹងការចូលរួមក្នុងសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ដែរ[36]។ បន្ទាប់មក អង្គជំនុំជម្រះបានជូនដំណឹងទៅមេធាវីការពារក្តីថា អង្គជំនុំជម្រះនឹងគាំទ្រដល់សំណើសុំធនធានបន្ថែមនេះ[37]។ មេធាវីការពារក្តី ខៀវ សំផន មិនបានដំណើរការទៅតាមមូលដ្ឋាននេះដើម្បីស្នើសុំធនធានដែលខ្លួនយល់ថាជាការចាំបាច់ ដើម្បីអនុញ្ញាតឱ្យពួកគេអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការឡើយ។ ផ្ទុយទៅវិញ មេធាវីការពារក្តី ខៀវ សំផន បែរជាដាក់សេចក្តីសន្និដ្ឋានផ្សេងៗក្នុងសំណុំរឿង ០០២/០២ ដែលមិនមែនជាការងារបន្ទាន់ ឬក៏មានសំណូមពរអ្វីនោះទេ[38]។

---

ធនធានបន្ថែមនៅដើមឆ្នាំ ២០១៤ ទេ។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ៣៦ ដល់ ៣៧ (ភាសាអង់គ្លេស)។ ថ្វីត្បិតតែយ៉ាងនេះក្តី ផ្នែករដ្ឋបាល និងអង្គជំនុំជម្រះមិនបានដឹងពីកង្វល់ពាក់ព័ន្ធនឹងធនធានទេ។ ដូចគ្នាដែរ ការដាក់សារណាដំបូងដែលចង្អុលបង្ហាញពីការខ្វះខាតបញ្ហាធនធានដែលបានលើកឡើងដោយមេធាវីការពារក្តី ខៀវ សំផន ជូនអង្គជំនុំជម្រះតុលាការកំពូលត្រូវបានធ្វើឡើងនៅខែ តុលា ឆ្នាំ ២០១៤។ *សំណើសុំឱ្យបង្គាប់ដល់ផ្នែករដ្ឋបាលពង្រឹងសមត្ថភាពរបស់អង្គភាពបកប្រែភាសាជាបន្ទាន់* ឯកសារ F8 ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១៤។

[34] ប្រតិចារឹក ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ១ (ភាសាអង់គ្លេស) (សម្ងាត់)។

[35] ប្រតិចារឹក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ២០ (ភាសាអង់គ្លេស)។

[36] ប្រតិចារឹក ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ៧ (ភាសាអង់គ្លេស) (អ្នកស្រី Anta GUISSÉ និយាយថា៖ “ក្រុមមេធាវី ខៀវ សំផន មិនបានចុះហត្ថលេខាលើឯកសារណាមួយដែលមានប្រសិទ្ធភាពថា ពួកគេនឹងចូលរួមពេញលេញក្នុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២/០២ និង បណ្តឹងសាទុក្ខទេ”)។

[37] សេចក្តីសម្រេចបន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៧។

[38] សំណើសុំមួយដែលទាក់ទងនឹងឯកសារពាក់ព័ន្ធនឹងអង្គហេតុនៃការរៀបការដោយបង្ខំ ដែលត្រូវតែពិចារណាជាអង្គហេតុចុងក្រោយសម្រាប់ការជំនុំជម្រះក្នុងសំណុំរឿង០០២/០២។ *សូមមើល* សំណើសុំបញ្ចូលឯកសារថ្មីរបស់លោក ខៀវ សំផន ក្នុងកិច្ចពិភាក្សាដេញដោល (លិខិតរបស់ 2-TCE-81) ឯកសារ E324 ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៤។ សំណើសុំពីរផ្សេងទៀតដែលមិនមានសំណូមពរអ្វីនោះទេ ប៉ុន្តែបែរជាជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅវិញ។ *សូមមើល* (“គោលជំហររបស់ ខៀវ សំផន”) កថាខណ្ឌ ៤៦។ លិខិតពីមេធាវីការពារក្តី ខៀវ សំផន។

២១. មេធាវីការពារក្ដី ខៀវ សំផន បានអះអាងនៅចំពោះមុខអង្គជំនុំជម្រះថា ការងាររបស់ពួកគេលើសារណាបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ រារាំងពួកគេមិនអាចឱ្យរៀបចំការងារសម្រាប់សវនាការក្នុងសំណុំរឿង ០០២/០២ បានទេ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលពួកគេស្នើសុំពន្យារពេលសម្រាប់ការដាក់សារណាលើបណ្ដឹងសាទុក្ខ នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ ហើយនិងខណៈពេលដែលមានការដឹងឮជាសាធារណៈថា កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ត្រូវបានកំណត់កាលបរិច្ឆេទក្នុងការចាប់ផ្ដើមសវនាការហើយនោះក៏ដោយ ក៏នៅក្នុងសារណាស្នើសុំពន្យារពេលនោះ ពួកគេមិនបានលើកឡើងអំពីការរៀបចំសម្រាប់សវនាការនៅក្នុងពេលតែមួយនោះដែរ។ ជាងនេះទៀត ពួកគេមិនបានជូនដំណឹងដល់អង្គជំនុំជម្រះតុលាការកំពូល ពីចេតនារបស់ខ្លួនក្នុងការបដិសេធមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០២ រហូតដល់ការដាក់សារណាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ រួចរាល់នោះទេ[39]។ ប្រសិនបើមេធាវីការពារក្ដី ត្រូវការពេលវេលាបន្ថែមទៀតក្នុងការធ្វើសេចក្ដីព្រាងសារណាលើបណ្ដឹងសាទុក្ខរបស់ខ្លួន ដោយសារតែពួកគេត្រូវចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ នោះ ពួកគេគួរតែជូនដំណឹងទៅអង្គជំនុំជម្រះតុលាការកំពូលពីបញ្ហានេះ។ ផ្ទុយទៅវិញ មេធាវីការពារក្ដីរង់ចាំរហូតដល់ថ្ងៃសវនាការដំបូងក្នុងសំណុំរឿង ០០២/០២ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូង និងភាគីផ្សេងៗទៀតបានរៀបចំអ្វីៗទាំងអស់រួចរាល់ហើយនោះ ទើបពួកគេជូនដំណឹងមកអង្គជំនុំជម្រះនេះថា ពួកគេនឹងមិនចូលរួមទេ។ ចំណុចនេះនាំឱ្យមានសំណួរនានា ពីការធ្វើជាតំណាងរបស់មេធាវីការពារក្ដីទាំងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល[40]។

២២. ដោយផ្អែកលើចំណុចដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះសន្និដ្ឋានថា ការលើកឡើងរបស់មេធាវីការពារក្ដី ដោយយកមូលហេតុដែលថាមិនមានធនធានគ្រប់គ្រាន់មកធ្វើជាយុត្តិកម្មតាមផ្លូវច្បាប់ចំពោះការរំលោភបំពានលើដីកាបង្គាប់របស់តុលាការ និងការធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីនោះ មិនមានមូលដ្ឋានផ្លូវច្បាប់នោះទេ។

---

[39] *ប្រៀបធៀប* សំណើលើកទីពីរសុំពន្យាពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ F6 ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ១៣ ("អាស្រ័យហេតុនេះ ក្រុមមេធាវីការពារក្ដី [នួន ជា] នឹងជាប់ដៃក្នុងបណ្ដឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០១ និងសវនាការលើអង្គសេចក្ដីនៅក្នុងសំណុំរឿង ០០២/០២ ក្នុងពេលតែមួយ")។

[40] *Réglement Intérieur National de la profession d'avocat* (បារាំង) មាត្រា ២១.៤.៣ ("*Tout en faisant preuve de respect et de loyauté envers l'office du juge, l'avocat défend son client avec conscience et sans crainte, sans tenir compte de ses propres intérêts ni de quelque conséquence que ce soit pour lui-même ou toute autre personne.*")។ ក្រមសីលធម៌គណៈមេធាវីកម្ពុជា មាត្រា ៣៧ ("មេធាវីមិនត្រូវប្រើជាដាច់ខាតនូវវិធីមិនស្មោះត្រង់ ហើយត្រូវគោរពវិធីតទល់គ្នា")។

## ៣.២ ភាពអាចចូលរួមបានរបស់ ខៀវ សំផន

២៣. នៅក្នុងសវនាការថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ មេធាវីការពារក្ដីបានគូសបញ្ជាក់ថា ជាការពិតបញ្ហាធនធានមិនមែនជាមូលហេតុចម្បង ដែលធ្វើឱ្យពួកគេបដិសេធមិនចូលរួមសវនាការនោះទេ ដោយពួកគេបែរជាសំអាងទៅលើលទ្ធភាពរបស់ ខៀវ សំផន ដែលមិនអាចចូលរួមកិច្ចដំណើរការនីតិវិធីទាំងពីរស្របពេលជាមួយគ្នាទៅវិញ[41]។ អង្គជំនុំជម្រះបានបដិសេធនូវអំណះអំណាងនេះ ដោយកត់សម្គាល់ពីយុត្តិសាស្ត្រច្បាប់អន្តរជាតិស៊ីសង្វាក់គ្នាដែលថា ការរៀបចំសេចក្ដីព្រាងសារណាលើបណ្ដឹងសាទុក្ខ គឺជាការងារបច្ចេកទេសដែលត្រូវពឹងផ្អែកជាចម្បងទៅលើមេធាវីដែលត្រូវបានតែងតាំង និងមិនពឹងផ្អែកទៅលើជនជាប់ចោទនោះទេ[42]។

២៤. នៅចំពោះមុខដីកាបង្គាប់របស់តុលាការនេះ មេធាវីការពារក្ដីបានដាក់ឯកសារមួយដែលជំទាស់ទៅនឹងសំអាងហេតុនៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយសំអាងជាពិសេសទៅលើសេចក្ដីសម្រេចមួយក្នុងរឿងក្ដី *Mladic* នៅតុលាការ ICTY[43]។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី *Mladic* បានបដិសេធផ្នែកមួយនៃសំណើសុំបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ ដោយសារ "ការចូលរួមក្នុងការរៀបចំមុនពេលសវនាការលើអង្គសេចក្ដីនៃរឿងក្ដីមួយ ក្នុងខណៈពេលដែលចូលរួមក្នុងដំណាក់កាលប្រកាសសាលក្រម ឬ ដំណាក់កាលប្ដឹងសាទុក្ខរបស់សវនាការលើកទីមួយ ក្នុងពេលតែមួយ អាចក្លាយជាបន្ទុកហួសហេតុ និងមិនយុត្តិធម៌ដល់ជនជាប់ចោទ និងអាចកំហិតលទ្ធភាពរបស់

---

[41] ប្រតិចារឹក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ៧ (ភាសាអង់គ្លេស) ("ដំបូង ដើម្បីឆ្លើយតបទៅនឹងលោកលោកស្រីចៅក្រម ខ្ញុំសូមលើកឡើងថា អ្វីៗដែលយើងខ្ញុំបាននិយាយកន្លងមកមិនមែនកើតចេញពីបញ្ហាធនធានទេ។ សំណើរនានាដែលយើងខ្ញុំបានស្នើ មានបំណងជួយឱ្យលោក ខៀវ សំផន អាចចូលរួមយ៉ាងពេញលេញក្នុងការការពារក្ដីរបស់ខ្លួនពាក់ព័ន្ធនឹងអនុស្សរណៈ:")។ ទំព័រ ១៣ (ភាសាអង់គ្លេស) ("[ខៀវ សំផន] បានប្រាប់លោកលោកស្រីចៅក្រមថា គាត់មិនអាចធ្វើរឿងទាំងពីរយ៉ាងក្នុងពេលតែមួយ ក្នុងដំណាក់កាលសំខាន់នៃការការពារក្ដីរបស់គាត់បានទេ។ នេះជាបញ្ហាសំខាន់ណាស់។ ខ្ញុំមិនដឹងថាហេតុអ្វីទេ អ្វីដែលគាត់បាននិយាយថា ទំនងដូចជាមានការភ្លេចភ្លាំងខ្លះ។ ខ្ញុំគិតថាវាជាការសំខាន់ ហើយវាជាចំណុចសំខាន់នៅក្នុងសំណើរបស់លោក ខៀវ សំផន")។

[42] សេចក្ដីសម្រេចបន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៤ *ដោយដកស្រង់ចេញពីរឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Boskoski និង Tarculovski* ចៅក្រមមុនបណ្ដឹងឧទ្ធរណ៍នៃតុលាការ ICTY សំណុំរឿងលេខ IT-04-82-A សេចក្ដីសម្រេចលើសំណើរបស់ Johan Tarculovski ដែលស្នើសុំពន្យាពេលដាក់សារណាបណ្ដឹងសាទុក្ខ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ២ (ភាសាអង់គ្លេស)។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Popovic និងជនផ្សេងទៀត* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY សំណុំរឿងលេខ IT-05-88-A សេចក្ដីសម្រេចលើសំណើសុំពន្យារពេល និងសុំការអនុញ្ញាតបន្ថែមការកំណត់ចំនួនអក្សរ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១០ ទំព័រ ៤ (ភាសាអង់គ្លេស)។

[43] គោលជំហររបស់ ខៀវ សំផន កថាខណ្ឌ ២០។

គាត់ក្នុងការចូលរួមក្នុងរឿងក្តីណាមួយក្នុងចំណោមនោះឱ្យមានប្រសិទ្ធភាព"[44]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានទទួលស្គាល់ថា ផ្ទុយទៅវិញ "ពេលវេលានៃកិច្ចដំណើរការនីតិវិធីក្នុងរឿងក្តីទីពីរអាចកែសម្រួលដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានពេលវេលាសមស្របក្នុងការរៀបចំការការពារក្តីរបស់ខ្លួន"។ ជាការពិត ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY យល់ឃើញថា ការធ្វើដូច្នេះនឹងពន្យារពេលសវនាការនៃរឿងក្តីទីពីរហួសហេតុ"[45]។

២៥. មេធាវីការពារក្តី ខៀវ សំផន មិនបានទទួលស្គាល់ពីភាពខុសគ្នាយ៉ាងច្រើនរវាង កាលៈទេសៈនៅក្នុងរឿងក្តី *Mladic* និងកាលៈទេសៈរបស់កូនក្តីខ្លួននោះទេ។ មេធាវីការពារក្តី ខៀវ សំផន មានពេលវេលាយ៉ាងច្រើនរួចទៅហើយ ដើម្បីរៀបចំសម្រាប់សវនាការ និងការរៀបចំសេចក្តីព្រាងលើបណ្តឹងសាទុក្ខរបស់ខ្លួន ទៅតាមការណែនាំរបស់ជនជាប់ចោទ។ ជនជាប់ចោទ និងមេធាវីការពារក្តីរបស់ខ្លួនមានរយៈពេល ១០ ខែ ចាប់ពីពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល និងការចេញសាលក្រមក្នុងសំណុំរឿង ០០២/០១ ដើម្បីរៀបចំសម្រាប់សវនាការក្នុងសំណុំរឿង ០០២/០២[46]។ ជាងនេះទៀត ជនជាប់ចោទ និងមេធាវីការពារក្តីរបស់ខ្លួនអាចចូលពិនិត្យមើលសំណុំរឿងយ៉ាងពេញលេញ ក្នុងដំណាក់កាលស៊ើបសួរដែលមានរយៈពេលជាងពីរឆ្នាំ (ដែលការអនុវត្តនេះមិនមាននៅក្នុងកិច្ចដំណើរការនីតិវិធីនៅតុលាការ ICTY នោះទេ) និងពេលវេលាជាច្រើនទៀតក្នុងការរៀបចំសម្រាប់សវនាការ មុនពេលមានសវនាការដំបូងក្នុងសំណុំរឿងនេះនៅឆ្នាំ ២០១១។ សវនាការដេញដោលលើភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ ត្រូវបានកំណត់កាលបរិច្ឆេទនៅក្នុងរយៈពេល ក្រោយពីការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០១ កាលពីថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ និងបន្ទាប់ពីការដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ ដែលត្រូវនឹងថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានកំណត់កាលបរិច្ឆេទធ្វើសវនាការត្រឹមតែ ៣ ថ្ងៃក្នុងមួយសប្តាហ៍ ដែលក្រោយមកកាត់បន្ថយបន្ថែមទៀតមកត្រឹម ២ ថ្ងៃក្នុងមួយសប្តាហ៍ ដើម្បីអនុញ្ញាតឱ្យជនជាប់ចោទ មានពេលវេលាបន្ថែមទៀតសម្រាប់ធ្វើការងារលើសារណាបណ្តឹងសាទុក្ខជាមួយមេធាវី

---

[44] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mladic* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY សំណុំរឿងលេខ IT-09-92-PT សេចក្តីសម្រេចលើសំណើរួមរបស់អយ្យការសុំបំបែកដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសុំកែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១ ("សេចក្តីសម្រេចបំបែករឿងក្តី *Mladic*") កថាខណ្ឌ ៣១ (ភាសាអង់គ្លេស)។

[45] សេចក្តីសម្រេចលើការបំបែករឿងក្តី *Mladic* កថាខណ្ឌ ៣២

[46] មេធាវីក៏សំអាងទៅលើអំណះអំណាងមួយដែលទាក់ទិននឹងតម្រូវការឱ្យមានការសម្របសម្រួលរវាងមេធាវីការពារក្តីពីរក្រុមជាកង្វល់មួយដែលថា មិនអាចអនុវត្តបាននៅទីនេះទេ។ សូម្បីតែពេលដែលមេធាវីប្រចាំការមានវត្តមានក្នុងរឿងក្តីនេះក៏ដោយ ក៏ពួកគេនឹងមិនជួយក្នុងក្រុមការពារក្តីដែរ តែផ្ទុយទៅវិញពួកគេនឹងបន្តភារកិច្ចនេះជាអចិន្ត្រៃយ៍ពីមេធាវីបច្ចុប្បន្ន ប្រសិនបើមេធាវីបច្ចុប្បន្នជ្រើសរើសមិនមកបង្ហាញខ្លួន។

របស់ខ្លួនបាន[47]។ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតលើសំណើសុំរបស់មេធាវីការពារក្ដី ខៀវ សំផន ដែលស្នើសុំពេលវេលាបន្ថែមទៀត សម្រាប់រៀបចំបណ្ដឹងសាទុក្ខរបស់ខ្លួន ដោយរួមទាំងចំនួន ២១ ថ្ងៃបន្ថែមទៀត សម្រាប់ការជូនដំណឹងពីបណ្ដឹងសាទុក្ខ និង ៣០ ថ្ងៃបន្ថែមទៀត សម្រាប់សារណាលើបណ្ដឹងសាទុក្ខរបស់ខ្លួន[48]។ ហេតុនេះ មានការជួយសម្រួលជាច្រើនដើម្បីឲ្យជនជាប់ចោទអាចមានពេលវេលាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងនីតិវិធីសវនាការ និងនីតិវិធីលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២ និងដើម្បីអាចណែនាំមេធាវីរបស់ខ្លួនក្នុងនីតិវិធីនីមួយៗបានផងដែរ។ នៅពេលជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ មេធាវីការពារក្ដី ខៀវ សំផន មិនបានបង្ហាញពីយុត្តិសាស្ត្រនានា ឬ មូលដ្ឋានអង្គហេតុណាមួយទេ ដែលអាចផ្ដល់យុត្តិកម្មដល់សំណូមពរដែលថា ជនជាប់ចោទ ឬ មេធាវីការពារក្ដីរបស់ខ្លួន មិនមានលទ្ធភាពក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ ក្នុងពេលជាមួយគ្នា ជាពិសេសដោយពិចារណាទៅលើការប្រែប្រួលដែលពួកគេបានធ្វើរួចហើយនោះទេ។

២៦. ហេតុដូច្នេះ កាលៈទេសៈបច្ចុប្បន្ននេះ មានស្ថានភាពនីតិវិធីខុសប្លែកគ្នាទាំងស្រុងពីរឿងក្ដី *Mladic*។ អង្គជំនុំជម្រះតុលាការកំពូលនៅ អ.វ.ត.ក បានតម្កល់សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ និងបានសម្រេចថា កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ នឹងត្រូវចាប់ផ្ដើមដំណើរការកាន់តែឆាប់កាន់តែប្រសើរ។ វាជាការចាំបាច់ដែលថា កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ធ្វើដំណើរឆ្ពោះទៅមុខស្របពេលជាមួយបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១។ ហេតុនេះ អង្គជំនុំជម្រះសន្និដ្ឋានថា ទឡ្ហីករណ៍របស់មេធាវីការពារក្ដីដែលថា ពួកគេអាចមិនអើពើចំពោះដីកាបង្គាប់របស់តុលាការ ក្នុងការចូលរួមផ្នែកទីពីរនៃសំណុំរឿងដែលត្រូវបានបំបែកដោយផ្អែកលើយុត្តិសាស្ត្រនេះ គឺធ្វើឡើងដោយគ្មានមូលដ្ឋានគតិយុត្តិ ឬមូលដ្ឋានអង្គហេតុមកសំអាងទេ។

## ៣.៣ កិច្ចសន្យាការងារ និងភារកិច្ចរបស់មេធាវីចំពោះកូនក្ដីរបស់ខ្លួន

២៧. ជាចុងក្រោយ នៅក្នុងលិខិតមួយច្បាប់ដែលបានផ្ញើជូនអង្គជំនុំជម្រះកាលពីថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ មេធាវីការពារក្ដី ខៀវ សំផន បានលើកឡើងថា ពួកគេត្រូវបន្តអនុវត្តតាមការណែនាំរបស់កូនក្ដីខ្លួន

---

[47] *សូមមើល* ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

[48] សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ និងសារណានៃបណ្ដឹងសាទុក្ខ (អ.ជ.ត.ក) ឯកសារ F3/3 ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤។ សេចក្ដីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្ដឹងសាទុក្ខ និងសារណាតប (អ.ជ.ត.ក) ឯកសារ F9 ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៤។

ដោយមិនចូលរួមក្នុងសំណុំរឿង ០០២/០២ ទោះបីជាសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ដែលបង្គាប់ឱ្យពួកគេមិនគោរពតាមការណែនាំទាំងនេះក៏ដោយ។ មេធាវីការពារក្ដីលើកឡើងថា ដីកានេះរំលោភបំពានទៅលើប្រការមួយចំនួនក្នុងកិច្ចសន្យាការងាររបស់ខ្លួនជាមួយអង្គការសហប្រជាជាតិ។ មេធាវីអះអាងថា ចំណុចនេះផ្ដល់យុត្តិកម្មដល់ការរំលោភបំពានទៅលើដីកាបង្គាប់របស់អង្គ-ជំនុំជម្រះឱ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធី។ ដោយមិនមានយោងទៅដល់បទប្បញ្ញត្តិណាមួយជាក់លាក់ក្នុងកិច្ចសន្យានោះ អង្គជំនុំជម្រះមិនអាចវាយតម្លៃទឡ្ហីករណ៍នេះពេញលេញបានទេ។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះកត់សម្គាល់ថា កិច្ចសន្យានេះតម្រូវឱ្យមេធាវីអនុវត្តតាមក្របខណ្ឌច្បាប់នៅ អ.វ.ត.ក រួមទាំងវិធានផ្ទៃក្នុងផងដែរ និងត្រូវមានវត្តមាននៅ អ.វ.ត.ក ក្នុងករណីចាំបាច់ ដើម្បីធ្វើជាតំណាងឱ្យមានប្រសិទ្ធភាពដល់ជនជាប់ចោទ និងនៅពេលមានការជូនដំណឹងសមស្របឱ្យមានវត្តមាននោះ[49]។

២៨. ភារកិច្ចរបស់មេធាវីក្នុងការរក្សាភាពស្មោះត្រង់ និងភារកិច្ចបម្រើផលប្រយោជន៍ល្អប្រសើរដល់កូនក្ដីរបស់ខ្លួនមិនអាចផ្ដល់យុត្តិកម្ម ដល់ការរំលោភបំពានម្ដងហើយម្ដងទៀតលើដីការបស់តុលាការ និងការបន្តរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីនោះទេ។ អង្គជំនុំជម្រះទទួលស្គាល់ថា ជាទូទៅភារកិច្ចទាំងនេះបង្កើតជាទំនាក់ទំនងរវាងមេធាវីនឹងកូនក្ដីទាំងស្រុង[50]។ ទោះជាយ៉ាងណាក្ដី មេធាវីនៅតែមានភារកិច្ចអនុវត្តតាម

---

[49] គំរូកិច្ចសន្យាផ្ដល់សេវាផ្នែកច្បាប់ ឯកសារ E320/2/2/1.1 ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៤។ អនុស្សរណៈអន្តរការិយាល័យ ពីការិយាល័យរដ្ឋបាលទាក់ទងនឹង ("សំណើសុំកិច្ចសន្យាផ្ដល់សេវាច្បាប់រវាងអង្គការសហប្រជាជាតិ និងសហមេធាវីការពារក្ដី ខៀវ សំផន" ឯកសារ E320/2/2/1 ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ២-៣ (ដោយកត់សម្គាល់ថា មេធាវីការពារក្ដី ខៀវ សំផន មានចុះហត្ថលេខាលើកិច្ចសន្យាការងារជាមួយ អ.ស.ប ដោយមានខប្រការដូចគ្នាបេះបិតនឹងខប្រការដែលមាននៅក្នុងលិខិតគំរូ)។

[50] *Réglement Intérieur National de la profession d'avocat* (បារាំង) មាត្រា ១.៣ ("*[l'avocat] respecte en outre, dans cet exercice, les principes d'honneur, de loyauté, de désintéressement, de confraternité, de délicatesse, de modération et de courtoisie*")។ តុលាការព្រហ្មទណ្ឌអន្តរជាតិ ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មេធាវី ("ដំណោះស្រាយ ICC-ASP/4/Res.1) ខែ ធ្នូ ឆ្នាំ ២០០៥ ("ក្រមសីលធម៌នៅតុលាការ ICC") មាត្រា ១៤ ("ទំនាក់ទំនងរវាងកូនក្ដី និងមេធាវី គឺជាការផ្លាស់ប្ដូរព័ត៌មាន និងការទុកចិត្តគ្នាដោយឥតលាក់លៀម ដោយចងកាតព្វកិច្ចដល់មេធាវីត្រូវបំពេញការងារដោយស្មោះត្រង់ នៅពេលទាក់ទងជាមួយកូនក្ដី។ នៅពេលទទួលភារកិច្ចនោះ គ្រប់ពេល មេធាវីត្រូវបំពេញការងារដោយភាពត្រឹមត្រូវយុត្តិធម៌ សុចរិតភាព និងស្មោះត្រង់ចំពោះកូនក្ដី")។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់ក្រុមមេធាវីការពារក្ដីដែលមានវត្តមាននៅចំពោះមុខតុលាការអន្តរជាតិ IT/125 REV.3 ខែ សីហា ឆ្នាំ ២០០៩ ("ក្រមសីលធម៌នៅតុលាការ ICTY") មាត្រា ៣(iv) ("មេធាវីមានភារកិច្ចស្មោះត្រង់ចំពោះកូនក្ដីរបស់ខ្លួន ស្របទៅតាមកាតព្វកិច្ចចំពោះតុលាការ ដើម្បីបំពេញការងារដោយឯករាជ្យភាព នៅក្នុងផ្នែករដ្ឋបាលតុលាការ")។ *ប្រៀបធៀប* ក្រមសីលធម៌មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៨ ("ទំនាក់ទំនងរវាងមេធាវី និងអតិថិជន គឺជាទំនាក់ទំនង

ដីកាបង្គាប់របស់តុលាការ និងបំពេញការងារដើម្បីប្រយោជន៍យុត្តិធម៌ផងដែរ[51]។ អំណះអំណាងរបស់មេធាវីដែលថា ពួកគេមានភារកិច្ចបម្រើផលប្រយោជន៍ដ៏ល្អបំផុតសម្រាប់កូនក្តីរបស់ខ្លួននោះ នាំឲ្យមានការចោទសួរចំពោះអង្គហេតុដែលថា ពួកគេស្ថិតនៅទីក្រុង ប៉ារីស ជាជាងនៅប្រទេសកម្ពុជា ក្នុងពេលភាគច្រើននៃថិរវេលាដែលយកមកពិភាក្សានេះ។ ជាងនេះទៀត មិនមានតុលាការ ឬប្រព័ន្ធយុត្តិធម៌ណាមួយដែលអត់ឱនចំពោះឥរិយាបថ ដែលឲ្យភាគីមួយកំណត់កាលវិភាគដោយខ្លួនឯងមកលើតុលាការ និងភាគីផ្សេងទៀតនោះទេ។ ពាក់ព័ន្ធនឹងការអះអាងដែលថា អង្គជំនុំជម្រះមិនអាចចាត់វិធានការណាដែលនឹងធ្វើឲ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់មេធាវីការពារក្តីនោះ អង្គជំនុំជម្រះសន្និដ្ឋានថា ឯករាជ្យភាពរបស់មេធាវីការពារក្តី អាចអនុវត្តបានដោយមានកម្រិតនៅក្នុងក្របខណ្ឌច្បាប់ជាធរមាននៅចំពោះមុខតុលាការ និងមិនត្រូវឲ្យប៉ះពាល់ដោយមិនសមស្របដល់សិទ្ធិរបស់ភាគីនានាប៉ុណ្ណោះ។ ហេតុនេះ អង្គជំនុំជម្រះសន្និដ្ឋានថា ការអះអាងដែលថា មេធាវីកំពុងអនុវត្តតាមការណែនាំរបស់កូនក្តីខ្លួន មិនមានមូលដ្ឋានសំអាងសម្រាប់ការពារខ្លួននោះទេ។

---

តាមកិច្ចសន្យា ហើយកិច្ចសន្យានោះមានប្រភពពីទំនៀមទម្លាប់ និងពីការព្រមព្រៀងគ្នាទៅវិញទៅមក។ មេធាវីគឺជាអ្នកកាន់តំណែងការពារ និងតំណាងឲ្យអតិថិជន")។

[51] វិធាន ២២(៤) នៃវិធានផ្ទៃក្នុង។ ក្រមសីលធម៌មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៧ ("មេធាវីត្រូវគោរពតាមវិធាននីតិវិធីនិងបទបញ្ជារបស់តុលាការ។ មេធាវីមិនត្រូវប្រើជាដាច់ខាតនូវវិធីមិនស្មោះត្រង់ ហើយត្រូវគោរពវិធីតទល់គ្នា។ មេធាវីមានសិទ្ធិសំដែងឡើងនូវអ្វីៗដែលខ្លួនយល់ថា មានប្រយោជន៍ដល់អតិថិជនរបស់ខ្លួន")។ មាត្រា ៣៩ ("មេធាវីមិនត្រូវបង្កឲ្យមានការពន្យារនីតិវិធីតុលាការណាមួយ ដោយការធ្វេសប្រហែស ឬ មូលហេតុមិនសមហេតុផលដែលអាចប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌នោះឡើយ")។ *Réglement Intérieur National de la profession d'avocat* (បារាំង) មាត្រា ២១.៤.១ ("*L'avocat qui comparaît devant les cours et tribunaux ou participe à une procédure doit observer les règles déontologiques applicables devant cette juridiction.*") មាត្រា ២១.៤.៣ ("*Tout en faisant preuve de respect et de loyauté envers l'office du juge, l'avocat défend son client avec conscience et sans crainte, sans tenir compte de ses propres intérêts ni de quelque conséquence que ce soit pour lui-même ou toute autre personne.*")។ ក្រមសីលធម៌នៅតុលាការ ICC មាត្រា ១៤(២) ("នៅពេលធ្វើជាតំណាងកូនក្តីណាម្នាក់ មេធាវីត្រូវ (ក) អនុវត្តតាមសេចក្តីសម្រេចរបស់កូនក្តីពាក់ព័ន្ធនឹងគោលដៅនៃការធ្វើជាតំណាង ដរាបណាសេចក្តីសម្រេចទាំងនោះស្របទៅនឹងភារកិច្ចមេធាវីអនុលោមតាមលក្ខន្តិកៈ វិធាននីតិវិធី និងភស្តុតាង និងក្រមនេះ")។ (គូសបញ្ជាក់បន្ថែម) មាត្រា ២៤(១) ("មេធាវីត្រូវមានវិធានការចាំបាច់ដើម្បីធានាថា ទង្វើរបស់ខ្លួន ឬទង្វើនានារបស់ជំនួយការមេធាវី ឬបុគ្គលិក មិនប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីកំពុងបន្ត និងមិននាំឲ្យតុលាការបាត់បង់កិត្តិយសទេ")។ ក្រមសីលធម៌នៅតុលាការ ICTY មាត្រា ៣(iv) មាត្រា ៨(គ) ("មេធាវីមិនត្រូវ ផ្តល់យោបល់ ឬជួយកូនក្តីក្នុងការប្រព្រឹត្តិដែលមេធាវីដឹងថាជាបទល្មើសព្រហ្មទណ្ឌ ឬទុច្ចរិត ជាការបំពានដល់លក្ខន្តិកៈ វិធាន ក្រមនេះ ឬច្បាប់ជាធរមានផ្សេងៗទៀត និងការណែនាំ នៅពេលដែលមេធាវីត្រូវបានតែងតាំងឲ្យតំណាងកូនក្តីរបស់ខ្លួន")។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Barayagwiza* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR សំណុំរឿងលេខ ICTR-97-19-T សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំដក សំណុំរឿងលេខ ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០០០ កថាខណ្ឌ ២១, ២៤ (ភាសាអង់គ្លេស)។

## ៣.៤ សេចក្តីសន្និដ្ឋាន

២៩. អង្គជំនុំជម្រះ បានដោះស្រាយបញ្ហាដែលមេធាវីមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ យ៉ាងប្រុងប្រយ័ត្នបំផុត។ អង្គជំនុំជម្រះបានផ្តល់ឱកាសនានាដល់មេធាវីការពារក្តី ខៀវ សំផន ឱ្យអនុវត្តតាមដីកាបង្គាប់របស់តុលាការ ដោយស្នើឱ្យមានការផ្តល់ធនធានបន្ថែម និង ការកាត់បន្ថយចំនួនថ្ងៃសវនាការផងដែរ។ អង្គជំនុំជម្រះបានធ្វើការព្រមានដោយផ្ទាល់អំពីផលវិបាកដែលអាចកើតមានដោយសារការប្រព្រឹត្តិរបស់ពួកគេ។ ប៉ុន្តែមេធាវីការពារក្តី ខៀវ សំផន នៅតែបន្តការប្រព្រឹត្តិរបស់ខ្លួនដែលមិនត្រូវបាន ផ្តល់យុត្តិកម្មដោយច្បាប់ ឬ ដោយកាលៈទេសៈនានានៃរឿងក្តីនេះ និងដែលផ្ទុយពីលទ្ធភាពរបស់មេធាវីការពារក្តី នួន ជា ដែលចូលរួមក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ។ មកទល់នឹងពេលនេះ លទ្ធផលនៃការបដិសេធរបស់ពួកគេក្នុងការមិនចូលរួមសវនាការ បានធ្វើឱ្យបាត់បង់ការជំនុំជម្រះចំនួន ២៥ ថ្ងៃ ក្នុងរយៈពេល ១០ សប្តាហ៍។ មេធាវីនៅតែបន្តដាក់សំណើដដែលៗ និងស្នើសុំការចំណាយបន្ថែម ខណៈដែលកង្វះការយកចិត្តទុកដាក់ក្នុងការងាររបស់ខ្លួន បានធ្វើឱ្យរាំងស្ទះដល់សវនាការដេញដោលលើភស្តុតាងស្តីពីទិដ្ឋភាពសំខាន់មួយក្នុងសម័យខ្មែរក្រហម ដែលទាក់ទងនឹងការប្រព្រឹត្តិចំពោះប្រជាជនកម្ពុជាធម្មតានៅតាមសហករណ៍នានា ដូចជានៅត្រាំកក់ជាដើម។

៣០. មេធាវីការពារក្តីបានទទួលស្គាល់ការប្រព្រឹត្តិនេះ ទោះបីជាពួកគេប៉ុនប៉ងធ្វើយុត្តិកម្មដល់ការប្រព្រឹត្តិរបស់ខ្លួន នៅក្នុងសារណាពីរដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះក៏ដោយ[52]។ ការលើកឡើងនៅក្នុងសារណាទាំងនេះជារឿងដដែលៗ គ្មានប្រយោជន៍ និងជាការគាំទ្រដល់យុទ្ធសាស្ត្រការពារក្តីដែលមិនមានមូលដ្ឋានតាមផ្លូវច្បាប់ មិនស្របទៅនឹងភារកិច្ចរបស់មេធាវីការពារក្តី និងបង្កជាការរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២។ ការអនុញ្ញាតឱ្យផ្តល់កម្រៃដល់មេធាវីចំពោះទង្វើទាំងនេះ ជាការគាំទ្រដល់ឥរិយាបថនេះ។ ហេតុនេះ អង្គជំនុំជម្រះពិចារណាថា វាជាការចាំបាច់ដែលត្រូវផ្តល់យោបល់ដល់អង្គភាពគាំពារការការពារក្តី ឱ្យបដិសេធមិនផ្តល់ប្រាក់កម្រៃចំពោះការងារនានាដែលបានស្នើសុំដោយមេធាវីការពារក្តី ខៀវ សំផន នៅក្នុងឯកសារទាំងពីរនេះ។

---

[52] ដូចបានពិភាក្សាខាងលើ ឯកសារទីមួយមានគោលបំណងតតាំងនឹងសេចក្តីសម្រេច និងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ដែលបានបដិសេធសទិទានភាពមួយដែលបានដាក់ដោយមេធាវីការពារក្តី ខៀវ សំផន សម្រាប់បដិសេធមិនមានវត្តមាននៅឯសវនាការនៅតុលាការ។ *សូមមើល*គោលជំហររបស់ ខៀវ សំផន។ ឯកសារទីពីរគឺជាលិខិតមួយច្បាប់ដែលបន្ថែមសំអាងហេតុដែលបានដាក់ក្នុងឯកសារទីមួយ។ *សូមមើល* លិខិតពីមេធាវីការពារក្តី ខៀវ សំផន។

៣១. អនុលោមតាមវិធាន ៣៨(២) អង្គជំនុំជម្រះក៏អាចបញ្ជូនទៅ "អង្គភាពមានសមត្ថកិច្ច" ចំពោះការប្រព្រឹត្តិរបស់មេធាវីដែលធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះកត់សម្គាល់ថា ពាក្យពេចន៍នៃបទប្បញ្ញត្តិនេះមានភាពទូលំទូលាយជាង ពាក្យពេចន៍ដែលមានចែងក្នុងបទប្បញ្ញត្តិនៃតុលាការអន្តរជាតិផ្សេងៗទៀត ហើយអាចអនុញ្ញាតឱ្យអង្គជំនុំជម្រះបញ្ជូនការប្រព្រឹត្តិនេះទៅអង្គភាពមានសមត្ថកិច្ចនៃតុលាការអន្តរជាតិ និងសាលាក្តីអន្តរជាតិបាន ដោយរួមមានអង្គភាពដែលទទួលខុសត្រូវរក្សាបញ្ជីឈ្មោះមេធាវីការពារក្តីផងដែរ[53]។ នៅពេលនេះ អង្គជំនុំជម្រះពិចារណាថា វាជាការសមស្របដែលត្រូវជូនដំណឹងដល់គណៈមេធាវីថ្នាក់ជាតិដែលពាក់ព័ន្ធ នូវការប្រព្រឹត្តិរបស់សមាជិកពួកគេ ដែលត្រូវបានចាត់ទុកថាផ្ទុយពីក្រមសីលធម៌ ឬពីវិជ្ជាជីវៈ ដូចដែលមានរៀបរាប់ក្នុងសេចក្តីសម្រេចនេះ[54]។ អាស្រ័យហេតុនេះ អង្គភាពមានសមត្ថកិច្ចដែលគួរបញ្ជូនកំហុសរបស់មេធាវី គង់ សំអុន គឺគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ហើយអង្គភាពមានសមត្ថកិច្ចដែលគួរបញ្ជូនកំហុសរបស់មេធាវី Arthur VERCKEN និងមេធាវី Anta GUISSÉ ក្នុងកម្រិតដំបូងគឺ ក្រុមប្រឹក្សាវិន័យនៃគណៈមេធាវីក្រុងប៉ារីស (Disciplinary Board of the Paris Bar Association)។ ក្នុងករណីចាំបាច់ អង្គជំនុំជម្រះក៏អាចបញ្ជូនការប្រព្រឹត្តិរបស់មេធាវីអន្តរជាតិទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។

## ផ្អែកតាមសំអាងហេតុនានាដែលបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង៖

**សន្និដ្ឋានថា** ការរំលោភបំពានលើដីកាបង្គាប់របស់តុលាការឱ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការដែលត្រូវបានកំណត់កាលបរិច្ឆេទ ដោយមេធាវី គង់ សំអុន មេធាវី Arthur VERCKEN និង មេធាវី

---

[53] *សូមមើលឧទាហរណ៍* វិធាន ៤៦(ខ) នៃតុលាការ ICTY វិធាន ៤៦(ខ) នៃ ICTR ដែលវិធានទាំងពីរនេះសំដៅដល់អង្គភាពមានសមត្ថកិច្ចដែលគ្រប់គ្រងការប្រព្រឹត្តិរបស់មេធាវីនៅក្នុង "ស្ថានភាពនៃការទទួលស្គាល់" របស់មេធាវី។

[54] *សូមមើល* វិធាន ១១(៤)(គ)(១) នៃវិធានផ្ទៃក្នុង (ត្រូវតែនៅក្នុងពេលបច្ចុប្បន្នជាសមាជិក ដែលមានកេរ្តិ៍ឈ្មោះល្អនៃគណៈមេធាវី ដែលត្រូវបាន ទទួលស្គាល់នៅក្នុងរដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ)។ *សូមមើលផងដែរ* (ច្បាប់បារាំង) *Loi n° 71-1130 du 31 décembre 1971 portant réforme de certaines professions judiciaires et juridiques* មាត្រា ២២ (*"Un conseil de discipline institué dans le ressort de chaque cour d'appel connaît des infractions et fautes commises par les avocats relevant des barreaux qui s'y trouvent établis. Toutefois, le Conseil de l'ordre du barreau de Paris siégeant comme conseil de discipline connaît des infractions et fautes commises par les avocats qui y sont inscrits[...]"* មាត្រា ២៣ (*"L'instance disciplinaire compétente en application de l'article 22 est saisie par le procureur général près la cour d'appel dans le ressort de laquelle elle est instituée ou le bâtonnier dont relève l'avocat mis en cause"*) មាត្រា ២៥ (*"Toute juridiction qui estime qu'un avocat a commis à l'audience un manquement aux obligations que lui impose son serment, peut saisir le procureur général en vue de poursuivre cet avocat devant l'instance disciplinaire dont il relève."*)។

Anta GUISSÉ (មេធាវីការពារក្ដី ខៀវ សំផន) បានធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៣៨ (១) នៃវិធានផ្ទៃក្នុង។

**សម្រេច** បញ្ជូនកំហុសវិជ្ជាជីវៈរបស់មេធាវី Arthur VERCKEN និង មេធាវី Anta GUISSÉ ទៅប្រធានគណៈមេធាវីក្រុងប៉ារីស និង អគ្គរដ្ឋអាជ្ញាសាលាឧទ្ធរណ៍ក្រុងប៉ារីស និងបញ្ជូនកំហុសវិជ្ជាជីវៈរបស់មេធាវី គង់ សំអុន ទៅប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អនុលោមតាមវិធាន ៣៨(២) នៃវិធានផ្ទៃក្នុង ក្នុងគោលបំណងឱ្យក្រុមប្រឹក្សាវិន័យនៃអង្គភាពទាំងនេះចាត់វិធានការ។

**ស្នើឲ្យ** ប្រធានគណៈមេធាវីក្រុងប៉ារីស អគ្គរដ្ឋអាជ្ញាសាលាឧទ្ធរណ៍ក្រុងប៉ារីស និង ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជូនដំណឹងមកអង្គជំនុំជម្រះវិញ នូវសេចក្ដីសម្រេចនានាដែលបានធ្វើឡើងទាក់ទងការបញ្ជូនកំហុសវិជ្ជាជីវៈមេធាវីនេះ ឱ្យបានឆាប់តាមតែអាចធ្វើទៅបាន ហើយក្នុងករណីដែលមិនមានចេញសេចក្ដីសម្រេច ក៏សូមជូនដំណឹងមកអង្គជំនុំជម្រះអំពីស្ថានភាពនៃការបញ្ជូនកំហុសវិជ្ជាជីវៈនេះដែរ យ៉ាងយូរត្រឹមថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ ។

**រម្លឹកឡើងវិញ** នូវវិធាន ១១(២)(ជ) ដែលអង្គភាពគាំពារការការពារក្ដី (អ.គ.ក) ទទួលខុសត្រូវ "ត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងារនៃគ្រប់កិច្ចសន្យាទាំងអស់ [...] និងអនុញ្ញាតឱ្យផ្ដល់ប្រាក់កម្រៃស្របទៅតាមលទ្ធផលការងារ ដូចមានចែងក្នុងបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្ដី"។

**ផ្ដល់អនុសាសន៍** ថា អង្គភាពគាំពារការការពារក្ដី គួរបដិសេធរាល់សំណើនានារបស់មេធាវីការពារក្ដី ខៀវ សំផន ដែលស្នើសុំផ្ដល់កម្រៃសម្រាប់ការងារដែលបានស្នើសុំក្នុងឯកសារ E320/1/1 និង E320/2/1 និង **បង្គាប់ឲ្យ** អង្គភាពគាំពារការការពារក្ដី រាយការណ៍មកអង្គជំនុំជម្រះវិញត្រឹមថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ ស្ដីពីវិធានការនានាដែល អ.គ.ក បានយកមកអនុវត្តតាមអនុសាសន៍នេះ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. E.C.C.C.

**និល ណុន**